សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងមហាអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលអាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។

ប៉ុន្តែ នៅពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរី តាមការដែលខ្លួនយល់ឃើញថាស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងមហាអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

## ផ្នែកទី ៣
## អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

### មាត្រា ៧១.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល គឺជាសេនាធិការឲ្យតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលលើៈ

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការសម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់តុលាការ
- ការងាររៀបចំគម្រោងថវិកាជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដើម្បីពិនិត្យ និងសម្រេច
- របាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលដីការបស់តុលាការកំពូលជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

- ការងារផ្សេងទៀតដែលប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ប្រគល់ឲ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត ។

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលបែងចែកជានាយកដ្ឋាន ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៧២.-**

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ។

អគ្គលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីលើកសំណើជូននាយករដ្ឋមន្ត្រី ។ អគ្គលេខាធិការត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធានការិយាល័យ ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានទាំងអស់ដោយរួមទាំងអគ្គលេខាធិការផង ត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

**មាត្រា ៧៣.-**

ស្តិទិបាតរបស់តុលាការកំពូល ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និង

កំណត់ទិសដៅការងាររដ្ឋបាលរបស់តុលាការកំពូលសម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់តុលាការកំពូល ត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៥
## វិសមិតភាព

**មាត្រា ៧៤.-**

មុខងារធ្វើបណ្តឹងអាជ្ញា មុខងារស៊ើបសួរ និងមុខងារជំនុំជម្រះ ត្រូវបែងចែកដាច់ពីគ្នា ។ ចៅក្រមណាម្នាក់ដែលបានទទួលបន្ទុកចាត់ការរឿងក្តីណាមួយក្នុងឋានៈជាតំណាងអយ្យការ ឬជាចៅក្រមស៊ើបសួររួចហើយមិនអាចជំនុំជម្រះ ឬចូលរួមជំនុំជម្រះរឿងក្តីដែលខ្លួនបានទទួលចាត់ការនោះឡើយ បើពុំដូច្នោះទេ សាលក្រម ឬសាលដីកានឹងត្រូវទុកជាមោឃៈ ។

**មាត្រា ៧៥.-**

ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្តីតែមួយជាមួយគ្នានឹងចៅក្រមម្នាក់ ឬច្រើននាក់ដែលជាសហព័ទ្ធ ឬញាតិលោហិត រហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផងទោះក្នុងឋានៈជាចៅក្រមជំនុំជម្រះក្តី ឬជាតំណាងអយ្យការក្តី ។ គោលការណ៍នេះត្រូវអនុវត្តដូចគ្នាផងដែរសម្រាប់ចៅក្រមនៅសាលាជម្រះក្តីជាន់ខ្ពស់ ចំពោះរឿងក្តីដែលត្រូវបានជំនុំជម្រះដោយចៅក្រមនៅសាលាជម្រះក្តីជាន់ទាបដែលជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ។

**មាត្រា ៧៦.-**

ចៅក្រមទាំងឡាយដែលមានសហព័ទ្ធ ឬញាតិលោហិត រហូតដល់ថ្នាក់ទី៤ (បួន) រាប់ ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ធ្វើជាមេធាវីឲ្យភាគីម្ខាងនៃរឿងក្តីណាមួយ មិនអាចចូលរួមជំនុំជម្រះរឿងក្តីនោះបានឡើយ ។

**មាត្រា ៧៧.-**

ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្តីណាមួយ ដែលមានភាគីម្ខាងជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី ៦ (ប្រាំមួយ) រាប់ទាំងថ្នាក់ទី ៦ (ប្រាំមួយ) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

**មាត្រា ៧៨.-**

លើកលែងតែមានបទប្បញ្ញត្តិស្តីពីនីតិវិធីចែងផ្សេងពីនេះ ភាគីទាំងឡាយនៅក្នុងរឿងក្តី និងបុគ្គលដែលមានប្រយោជន៍ក្នុងរឿងក្តី ដោយរួមទាំងតំណាងអយ្យការផង អាចប្តឹងសុំមោឃកម្មចំពោះសាលក្រម ឬសាលដីការបស់តុលាការ ដោយហេតុបំពានវិធានស្តីពីវិសមិតភាពដូចមានចែងក្នុងមាត្រា ៧៤ មាត្រា ៧៥ មាត្រា ៧៦ និងមាត្រា ៧៧ ខាងលើ ។

បណ្តឹងសុំមោឃកម្មនេះ អាចធ្វើបានគ្រប់ពេលវេលា នៅចំពោះមុខតុលាការ នៅក្នុងនីតិវិធីឧបាស្រ័យដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។ បើទោះបីជាសាលក្រមឬសាលដីកានោះបានចូលស្ថាពរហើយក៏ដោយ ក៏បណ្តឹងសុំមោឃកម្ម នៅតែអាចធ្វើឡើងបានដដែលក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃបានដឹងអំពីមូលហេតុដូចមានចែងក្នុងមាត្រា ៧៤ មាត្រា ៧៥ មាត្រា ៧៦ និងមាត្រា ៧៧ ខាងលើក្រោយពេលសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ ។ ក្នុងករណីចុងក្រោយនេះ បណ្តឹងសុំមោឃកម្ម ត្រូវដាក់នៅសាលាជម្រះក្តីដែលបានចេញសាលក្រម ឬសាលដីកាស្ថាពរ ប៉ុន្តែ ត្រូវមានសមាសភាពថៅក្រមជំនុំជម្រះផ្សេងដើម្បីពិនិត្យ និងសម្រេចអំពីមោឃកម្មនៃសាលក្រម ឬសាលដីកាស្ថាពរនោះ និងអនុវត្តនីតិវិធីបន្តស្របតាមបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៦
## ថវិកាសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី

**មាត្រា ៧៩.-**

សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ ។

ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៨០.-**

សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ព្រមទាំងអង្គការអយ្យការនៅអមសាលាជម្រះក្តីទាំងនេះ ដែលត្រូវបានបង្កើតឡើង នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តដំណើរការរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨១.-**

បទប្បញ្ញត្តិពីមុនពាក់ព័ន្ធនឹងតុលាការយោធា និងអយ្យការអមតុលាការយោធា ព្រមទាំងបទប្បញ្ញត្តិស្ដីពីសមត្ថកិច្ច និងនីតិវិធី ដែលអនុវត្តសម្រាប់ដំណើរការរឿងក្ដីបទល្មើសយោធា ត្រូវបន្តមានអានុភាពអនុវត្តក្រោយច្បាប់នេះចូលជាធរមាន រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស ។

**មាត្រា ៨២.-**

នៅពេលរង់ចាំការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍ផ្សេងទៀត សាលាឧទ្ធរណ៍បច្ចុប្បន្នដែលមានទីតាំងនៅរាជធានីភ្នំពេញ មានសមត្ថកិច្ចដែនដីលាតសន្ធឹងលើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨៣.-**

ការដាក់ឲ្យដំណើរការតុលាការជំនាញនានារបស់សាលាដំបូងដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៨៤.-**

ក្នុងករណីដែលសាលាដំបូងនៃខេត្តណាមួយមិនទាន់ត្រូវបានដាក់ឲ្យដំណើរការ ឬមិនអាចដាក់ឲ្យដំណើរការបាន សមត្ថកិច្ចជំនុំជម្រះរឿងក្ដីទាំងឡាយនៅក្នុងខេត្តនោះ ត្រូវប្រគល់ទៅឲ្យសាលាដំបូងណាមួយដោយព្រះរាជក្រឹត្យ ។

**មាត្រា ៨៥.-**

កាលបើសភាពាណិជ្ជកម្ម និងសភាការងារនៃសាលាជម្រះក្ដីជាន់ខ្ពស់ មិនអាចដំណើរការបានដោយមូលហេតុខ្វះចៅក្រម ការជំនុំជម្រះរឿងក្ដីពាណិជ្ជកម្ម និងរឿងក្ដីការងារ គឺជាសមត្ថកិច្ចនៃសភារដ្ឋប្បវេណីនៃសាលាជម្រះក្ដីជាន់ខ្ពស់ ។ កិច្ចការទាំងនេះ ត្រូវចាត់ចែងដោយប្រធានសាលាជម្រះក្ដីជាន់ខ្ពស់ ដែលសភាជំនាញនោះស្ថិតនៅ ។

កាលបើសភាជំនាញណាមួយខាងលើមានដំណើរការស្របតាមច្បាប់នេះ សភាជំនាញផ្សេងទៀតត្រូវផ្ទេររឿងក្ដីដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ហើយមិនទាន់ចាត់ការ ទៅសភាជំនាញដែលមានសមត្ថកិច្ចវិញ ។

**មាត្រា ៨៦.-**

ក្នុងករណីដែលមិនទាន់មានចៅក្រមគ្រប់គ្រាន់ ចៅក្រមស៊ើបសួរអាចបំពេញមុខងារជាចៅក្រមជម្រះក្ដីបាន ប៉ុន្តែ មិនអាចជំនុំជម្រះរឿងក្ដីដែលខ្លួនស៊ើបសួរបានឡើយ ។

**មាត្រា ៨៧.-**

ក្នុងករណីមិនទាន់មានសាលាជម្រះក្តីរដ្ឋបាល សមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋបាលត្រូវប្រគល់ឲ្យតុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ទាប និងសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់ ។

**មាត្រា ៨៨.-**

នៅពេលដែលមិនទាន់មានទីប្រឹក្សាពាណិជ្ជកម្ម ឬទីប្រឹក្សាការងារ សមាសភាពជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីការងារ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

**មាត្រា ៨៩.-**

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្មត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីការងារការជំនុំជម្រះរឿងក្តីការងារ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល ការជំនុំជម្រះរឿងក្តីរដ្ឋបាលត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

**មាត្រា ៩០.-**

ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំដំបូងបន្ទាប់ពីច្បាប់នេះចូលជាធរមាន ការតែងតាំងថ្នាក់ដឹកនាំនៃអង្គភាពរដ្ឋបាលរបស់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ អាចអនុវត្តបានយោងទៅតាមលក្ខខណ្ឌគុណវុឌ្ឍិជាក់ស្តែង ។

នាយកក្រឡាបញ្ជីនៃសាលាដំបូង អាចត្រូវបានតែងតាំងជាប្រធាន ឬអនុប្រធាននៃលេខាធិការដ្ឋានរដ្ឋបាលនៃសាលាដំបូងដែលខ្លួនកំពុងបំពេញការងារនោះបាន ។

នាយកក្រឡាបញ្ជីនៃសាលាជម្រះក្តីជាន់ខ្ពស់ អាចត្រូវបានតែងតាំងជាអគ្គលេខាធិការ ឬអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលនៃសាលាជម្រះក្តីជាន់ខ្ពស់ ដែលខ្លួនកំពុងបំពេញការងារនោះបាន ។

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៩១.-**

បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និងច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជាដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.០៧.៧៥២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខៈ ៩០៣ ស.ណ

**សំណៅដែលមានអង្គដើមជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៤៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តម្លើងឋានន្តរស័ក្តិ មន្ត្រីរាជការ ៥រូប នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសុខាភិបាល :

| | |
|---|---|
| ១- លោកជំទាវ **យក់ សម្បត្តិ** | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៥<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ ៥ |
| ២- លោកជំទាវ **ឱ ចណ្ណាឌីន** | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៦<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ ៦ |
| ៣- ឯកឧត្តម **អ៊ូ ចិត្តពា** | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ ៦ |
| ៤- ឯកឧត្តម **ឈាង រ៉ា** | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ ៦ |
| ៥- ឯកឧត្តម **ស៊ី សំអូរ** | ពីវរមន្ត្រី ថ្នាក់លេខ ៦ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

**មាត្រា ២** : តម្លើងក្របខ័ណ្ឌ និងឋានន្តរស័ក្តិ មន្ត្រីរាជការ ៣រូប ជាករណីពិសេស ពីឋានន្តរស័ក្តិនាយក្រមការ មកឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសុខាភិបាល :

១- លោកស្រី **អ៊ឹង រ៉ាដា** ពីនាយក្រមការ ថ្នាក់លេខ ១ មកអនុមន្ត្រី ថ្នាក់លេខ ៤

២- លោក **ឡាយ សុធី** ពីនាយក្រមការ ថ្នាក់លេខ ១ មកអនុមន្ត្រី ថ្នាក់លេខ ៦

៣- លោកស្រី **ញ៉ែម ឆេងហួន** ពីនាយក្រមការ ថ្នាក់លេខ ១ មកអនុមន្ត្រី ថ្នាក់លេខ ៦

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកត.០៦១៤.៩០២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៩០៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **ស៊ាង ហួង**
២- លោកជំទាវ **ឆា សុខអេង**
៣- លោកជំទាវ **ខ្លឹង ផល្លី**
៤- វរសេនីយ៍ឯក **យន ស្រីនាង**
៥- លោក **ប្រាជ ខែម៉េង**
៦- លោក **សុខ សុត្ថា**
៧- លោក **ឈេង លី**
៨- លោក **ម៉ៅ ធំ**
៩- លោក **សែ សុឃន**
១០- លោក **ហេង ប្រាង**
១១- លោក **ជា សំបូរ**

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- វរសេនីយ៍ឯក **ចាន់ អូន**
២- លោក **គិន សុភក្រ្ត**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- ឧត្តមសេនីយ៍ត្រី **ប៊ុណ្ណ សំខាន់**
២- ឧត្តមសេនីយ៍ត្រី **ប្រាក់ ផាដេត**
៣- ឧត្តមសេនីយ៍ត្រី **អ៊ុច សារុន**
៤- ឧត្តមសេនីយ៍ត្រី **ឆូ ឌុល**
៥- ឧត្តមសេនីយ៍ត្រី **ឆឹម ថង្សៃ**
៦- ឧត្តមសេនីយ៍ត្រី **នាង និនរត្ន**
៧- ឧត្តមសេនីយ៍ត្រី **ឃឹម សុវណ្ណ**
១១- វរសេនីយ៍ឯក **ញឹម សារិទ្ធ**
១២- វរសេនីយ៍ត្រី **អ៊ុំ តារ៉ែន**
១៣- វរសេនីយ៍ត្រី **ទេព សុវណ្ណ**
១៤- អនុសេនីយ៍ឯក **សេង សៀវលី**
១៥- អនុសេនីយ៍ឯក **ប៊ុក ប៉ូរ៉ា**
១៦- អនុសេនីយ៍ទោ **ម៉ុន ម៉ឿន**
១៧- អនុសេនីយ៍ទោ **ម៉េត សំណាង**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨- ឧត្តមសេនីយ៍ត្រី **ឃុន សារុធ**
៩- វរសេនីយ៍ឯក **នុត ប៊ុនធឿន**
១០- វរសេនីយ៍ឯក **ណុប មនិន្ទ**
១៨- លោក **គួច យូហុង**
១៩- លោក **ថេង ម៉ុងហាក់**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- ឯកឧត្តមវេជ្ជបណ្ឌិត **ហេង ថ្វាង**
២- ឯកឧត្តមឱសថការី **ម៉ក់ សុផល**
៣- លោកឱសថបណ្ឌិត **ឡៀម ណារិន**
៤- លោកទន្តបណ្ឌិត **កែវ ឌីណាម៉ូរ៉ា**
៥- វរសេនីយ៍ត្រី **គ្រាក់ ផល្លី**
៦- វរសេនីយ៍ត្រី **សុខ សុភាព**
៧- វរសេនីយ៍ត្រី **ព្រឿង សុវណ្ណរ័ត្ន**
៨- វរសេនីយ៍ត្រី **ស៊ុម ឌ៉ារី**
៩- អនុសេនីយ៍ឯក **អ៊ី ឈុនណារិទ្ធ**
១០- លោកឱសថការី **ហួត សេងថុង**
១១- លោកឱសថការី **អោក សុផល**
១២- លោក **នេង នៃ**
១៣- លោក **នៅ ចន្ថី**
១៤- លោក **ម៉ោះ បូណា**
១៥- អនុសេនីយ៍ឯក **ហ៊ូ ប៊ុនណែល**
១៦-អនុសេនីយ៍ឯក **សួស មិថុនា**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោក **មុំ សារ៉ានី**
២- លោក **ចាន់ បូរ៉ាដែត**

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១- លោកវេជ្ជបណ្ឌិត **យូ ពិសិដ្ឋ**
២- វរសេនីយ៍ទោ **ពុធ ឡេហេង**
៣- កញ្ញា **ឈឹម អ៊ុយទិច្ចិកា**
៤- លោក **ហុង សីហារាជ**
៥- លោក **យូ សុខចំរើន**
៦- លោក **ផុន នរាជ**
៧- កញ្ញា **ឈឿង ពិសិដ្ឋ**
៨- លោក **ម៉ាន ចណ្ណារ៉ុង**
៩- លោក **ស អឿមស្រស់**
១០- លោក **ម្ធូរ ចិន្ត្រា**
១១- លោក **ឃេង ដារ៉ា**
១២- កញ្ញា **ម៉ែន ចាន់រដ្ឋា**
១៣- លោក **ហាក់ ម៉ុន្នីស័រ**
១៤- កញ្ញា **ឈឹម ស្រីល័ក្ខ**
១៥- កញ្ញា **ឡាយ សុផាត់**
១៦- កញ្ញា **សាន់ រតនា**
១៧- កញ្ញា **នី និត្យថាវ័ត្ត**
១៨- លោក **អ៊ូ ចំរុង**
១៩- លោក **ផន យ៉ឿប**
២០- លោក **ជា បញ្ញា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស.១៤០៦.៩០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤

លេខ: ៦៥៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៨០

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ត្រាស់បង្គាប់**

**តែងតាំង**

**អ្នកម្នាង ស៊ីសុវត្ថិ សៀង ធី**

**ជា**

**ឯកអគ្គរាជទូតអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ**
**មានឋានៈស្មើ អនុរដ្ឋលេខាធិការ**

៣៧៩. ១៤០៦.០១៤
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៤*

**នរោត្ដម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ៤១៣៥/១៤. រ.ចប
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៤
សម្ដេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្ដារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៩៦

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

១- ដូនជី សីលចុម្ពាចារិនី អ៊ុំម សួន
២- ដូនជី មុច្ចលីន តែម លីន
៣- ឧបាសិកា អ៊ូច ខឹន
៤- ដូនជី ធម្មរក្សា ធា សាយ ឡេច
៥- ដូនជី ធម្មវត្តិកា ពូ សុម៉ារី
៦- ដូនជី ធម្មប្រិយ ស៊ឹង ទូច
៧- ដូនជី ចារុវណ្ណា សុខ ចម
៨- ឧបាសក ពូនី សាយខាំ
៩- ឧបាសក ឆិន អង់ឡាត់
១០- ឧបាសិកា ម៉ង ញ៉ឹន
១១- ឧបាសក សែម ណាថ
១២- ដូនជី បុញ្ញាចរិ ហួត សារ៉ាន់
១៣- ឧបាសិកា ម៉ង ស៊ុងគីន
១៤- ឧបាសក ឈាង សំអាង
១៥- ឧបាសក អង់ ដ៉ាត់
១៦- ឧបាសិកា សុធាត់ អេចេង
១៧- ឧបាសិកា សាមើន ទីជ ហួន
១៨- ឧបាសិកា ជីជ ណារ៉ា

៣៧.១៤០៦.៧០៥
បានប្រដាប់ព្រះរាជលញ្ចករហើយ
*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៤*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ [illegible] រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៤
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីរាជការ ៨ រូប ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេស ជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចាប់ពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ | ថ្នាក់ |
|---|---|---|---|
| ១ | លោក ប៊ុត រតនៈ | អនុមន្ត្រី | ថ្នាក់លេខ ១៤ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ២ | លោក ម៉ត់ ចាន់តារ៉ា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៣ | លោកស្រី សោម ច័ន្ទធទី | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ១៤ |
| ៤ | លោក កែម សុវណ្ណារ៉ូ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ១៤ |
| ៥ | លោក ស៊ុត រ៉ាដា | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ១៤ |
| ៦ | លោក សុត ទិសាល | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ១៤ |
| ៧ | លោក ហែម សីហៈ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ១៤ |
| ៨ | លោក សូ ដេត | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ១៤ |

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.១៤០៦.៥០៦

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៥៧១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល



**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៩៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ២២ រូប ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងយុត្តិធម៌ ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ | ថ្នាក់ |
|---|---|---|---|
| ១ | លោក ជា ឆៃទីរៈ | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ២ | លោកស្រី ជា សុតា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៣ | លោក ឌី វ៉ែង | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៤ | លោក ថន បញ្ញា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៥ | លោក យ៉ាន់ ចាន់និត | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៦ | លោកស្រី រ៉ាន់ ចណ្ណាដេត | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៧ | លោក លាង ឡុងឌី | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៨ | លោក សន សំនិត | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៩ | លោកស្រី ស៊ិន សោភា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១០ | លោកស្រី ស៊ឹម លក្ខិណា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១១ | លោក សឹង ច័ន្ទរដ្ឋា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១២ | លោកស្រី សុខ ធីតា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១៣ | លោក សួង ម៉ុនថា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១៤ | លោក សួស មិត្យារ៉ាន់ឌី | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១៥ | លោកស្រី ហួត ចន្ធី | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១៦ | លោកស្រី ហេង ស៊ីណែត | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១៧ | លោក ខៀវ រិទ្ធី | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១៨ | លោក ឃឹម ម៉ាលីយ៉ា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ១៩ | លោកស្រី ម៉ុរ សាមឌី | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ២០ | លោកស្រី ផូ ស្រីនាង | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ២១ | លោកស្រី ហែម ម៉ូលីកា | អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ២២ | លោកស្រី សុខ អាចស្រីលក្ខណ៍ | អនុមន្ត្រី | ថ្នាក់លេខ ១៤ |

មាត្រា ២ : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ព្រះហស្ថលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

នស.រកត.០៦១៤.៤០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤

លេខ: ៥៧០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** ប្តូរប្រភេទក្របខ័ណ្ឌតាមរយៈការប្រឡងប្រជែង ជូនមន្ត្រីរាជការ ៣៣រូប ពីក្របខ័ណ្ឌលេខាធិការរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ មកក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ពីក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម និងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន មកក្នុងក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ :

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ថ្មី |
|---|---|---|---|
| **ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល** | | | |
| ១ | លោក **ខេង សំបូរ** | ក្រមការដើមខ្សែ ថ្នាក់លេខ ៨ | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២ | កញ្ញា **អ៊ុំ សៅលី** | ក្រមការ ថ្នាក់លេខ ៨ | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣ | លោកស្រី **មូ ច័ន្ទទាសនា** | ក្រមការដើមខ្សែ ថ្នាក់លេខ ៨ | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| [illegible] | លោក **ញឹក ផល្លី** | នាយក្រមការ ថ្នាក់លេខ ១ | អនុមន្ត្រី ថ្នាក់លេខ ៣ |
| ៥ | លោក **ជា ស៊ានហុង** | ក្រមការដើមខ្សែ ថ្នាក់លេខ ៨ | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៦ | លោក **ផល មិច្ចសិរិទ្ធ** | លេខាធិការរដ្ឋបាល ថ្នាក់លេខ ១២ | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| [illegible] | លោក **ហេង ម៉ុនថា** | ក្រមការ ថ្នាក់លេខ ១១ | អនុមន្ត្រី ថ្នាក់លេខ ១៤ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៨ | លោក **និន ចណ្ណៈ** | ក្រមការដើមខ្សែ ថ្នាក់លេខ ៩ | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៩ | លោក **សុភ ម៉ូរ៉ា** | ក្រមការដើមខ្សែ ថ្នាក់លេខ ៨ | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ១០ | លោក **លឹក ផល្លា** | លេខាធិការរដ្ឋបាល ថ្នាក់លេខ ១២ | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| **ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម** | | | |
| ១១ | លោកស្រី **ផង់ ពុទ្ធី** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៩ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ១២ | លោកស្រី **សុខ ចាន់ផល្គុន** | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១១ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ១៣ | លោក **នៅ សុមនា** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៩ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ១៤ | លោកស្រី **អៀង សុចន្ធី** | គ្រូបង្រៀនកម្រិតបឋមដើមខ្សែពិសេស ថ្នាក់លេខ ៦ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ១៥ | លោក **សួរ ឡាដាំង** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៨ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ១៦ | លោក **មុត ចិន្តា** | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១១ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ១៧ | លោក **មឹង ចិរិយា** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៨ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ១៨ | លោក **មណ្ណា រម្យមនោ** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ១០ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ១៩ | លោក **ឈួ ចិសេស** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស ថ្នាក់លេខ ៦ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ |
| ២០ | លោក **ម៉ឹង មណ្ណារ** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៨ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ២១ | លោក **នាក់ មុន្នី** | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១១ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ២២ | លោក **ពុធ សំអាត** | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១០ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ២៣ | លោក **លី គីមលៀង** | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១៤ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ២៤ | លោក **ហ៊ា ស៊ុនណាត** | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១៣ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ២៥ | លោក **នាង សាក់** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៩ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ២៦ | លោក **ដួប គីមសាន** | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១០ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |

| | | | |
|---|---|---|---|
| ២៧ | លោក **ទុយ ឡាលីន** | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១៣ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ២៨ | លោក **ណុប ខៃ** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ១០ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ២៩ | លោក **ស៊ឹម អេខ** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៧ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ៣០ | លោកស្រី **សុខ សុទ្ធី** | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ១២ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ៣១ | លោក **ជុំ ខន្យច័ន្ទ** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ១០ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ៣២ | លោកស្រី **ហាន រតនា** | គ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ ១០ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤ |
| ៣៣ | លោក **ពុំ ចាន់ថា** | គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៦ | គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៣ |

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០៦១៤.៥០៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤*

លេខៈ ៨៤៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៩៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៤រូប ជាករណីពិសេស ពីឋានន្តរស័ក្តិអនុមន្ត្រី និងវរមន្ត្រី មកឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ១ | លោកជំទាវ **ស៊ិន សារ៉ោន** | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២ | ឯកឧត្តម **សំហោង ប៊ុរ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣ | លោកជំទាវ **ប៊ូ សោភ័ណ** | ពីអនុមន្ត្រី ថ្នាក់លេខ ១២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤ | ឯកឧត្តម **កែវ ចិន្តា** | ពីអនុមន្ត្រី ថ្នាក់លេខ ១៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១៤០៦.៧០៥

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៨៧៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ប្រគល់ភារកិច្ចជូនលោកជំទាវ **មិន ចណ្ឌីណែត** ឲ្យបំពេញមុខងារជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសាសនា នៅក្រសួងធម្មការ និងសាសនា ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៧-១៤០៦.៥១០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤*

លេខៈ ៨១៦ ស.ណ
**សំណៅដែលមានតម្លៃជាការចេញផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងថ្នាក់ឯកឧត្តម **ម៉ែន ស៊ីម៉ន** ជាករណីពិសេស ពីឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣ មកឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៤ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៤០៦. ៥១១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៨៧៤ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៦៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៣៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **ខេង សៅវិបុត្ត** អត្តលេខ ១៦១៩៩ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣៧.១៤០៦.៩១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៨២៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៧៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ចាន់ ឃាង** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ ដោយមិនយកប្រាក់បៀវត្ស** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរជ. ១៤០៦. ៤១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ៤២៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៨០០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំជាថ្មីនូវគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈ ប្រធាន អនុប្រធាន និងសមាជិក សមាជិកា នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ២៣ រូប ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ម៉ក់ សម្បត្តិ | ជាប្រធាន | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២- | ឯកឧត្តម | អ៊ីវ កាន | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម | អ៊ុត វ៉ាឌី | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤- | ឯកឧត្តម | ជេត ជាលី | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥- | ឯកឧត្តម | គិច ច័ន្ទតារា | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៦- | ឯកឧត្តម | អ៊ុច សេង | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៧- | ឯកឧត្តម | ស្រ៊ុន ធារិទ្ធ | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៨- | លោកជំទាវ | ពុំ ចន្ទីនី | ជាសមាជិកា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៩- | ឯកឧត្តម | ហង្ស ឡាវ៉ាម៉ានី | ជាសមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ១០- | ឯកឧត្តម | នូ ស្ថាបត្យា | ជាសមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ១១- | ឯកឧត្តម | ប៉ែន សិន | ជាសមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

១២- ឯកឧត្តម អ៊ុក វណ្ណារិទ្ធ ជាសមាជិក មានឋានៈស្មើ រដ្ឋលេខាធិការ
១៣- ឯកឧត្តម កត្តា អ៊ិន ជាសមាជិក មានឋានៈស្មើ រដ្ឋលេខាធិការ
១៤- លោកជំទាវ សុទ្ធ សុម៉ាលី ជាសមាជិកា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៥- ឯកឧត្តម ពេញ ជារម្យ ជាសមាជិក មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៦- ឯកឧត្តម សៅ លី ជាសមាជិក មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៧- ឯកឧត្តម ស៊ុន ហេង ជាសមាជិក មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៨- ឯកឧត្តម ខៀវ ពៅ ជាសមាជិក មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៩- ឯកឧត្តម លី ស៊ីណា ជាសមាជិក មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២០- ឯកឧត្តម ឈាង ជាន់ណារិទ្ធ ជាសមាជិក មានឋានៈស្មើ អគ្គនាយក
២១- ឯកឧត្តម ព្រំ សំអុល ជាសមាជិក មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២២- ឯកឧត្តម អៀវ តឺរី ជាសមាជិក មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៣- ឯកឧត្តម ចាន់ វិចិត្រ ជាសមាជិក មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាអគ្គនាយកនៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា៖
១- ឯកឧត្តម ឡេង តុលា ជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងពាក្យបណ្ដឹង
២- ឯកឧត្តម វ៉ាន់ ច័ន្ទតារា ជាអគ្គនាយកនៃអគ្គនាយកដ្ឋានស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្ស

**មាត្រា ៣** : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០៦១៤.៥៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៨១៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..៧១៧..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងសន្តិសុខអាកាសចរស៊ីវិល
# នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសន្តិសុខអាកាសចរស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់វិធានការការពារ សន្តិសុខ និងសុវត្ថិភាពដល់អ្នកដំណើរ ក្រុមអាកាសយានិក បុគ្គលិកបម្រើការងារលើផ្ទៃដី សាធារណជនទូទៅ អាកាសយាន អាកាសយានដ្ឋានអន្តរជាតិ អាកាសយានដ្ឋានមូលដ្ឋាន ឋបនីយភណ្ឌអាកាសយានដ្ឋាន និងប្រឆាំងអំពើរំលោភបំពានច្បាប់ ទាំងនៅលើផ្ទៃដី ទាំងនៅពេលកំពុងហោះហើរ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាព អនុវត្តលើការងារគ្រប់គ្រងសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ អាកាសយានដ្ឋានមូលដ្ឋាន ក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស ក្រុមហ៊ុនផ្ដល់សេវាកម្មអាកាសចរ ក្រុមហ៊ុនផ្សេងៗទៀត ដែលផ្ដល់សេវាកម្មនៅអាកាសយានដ្ឋាន និងកិច្ចប្រតិបត្តិការអាកាសយានគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

**កម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល** សំដៅដល់គោលការណ៍ណែនាំដែលមានលក្ខណៈជាបទប្បញ្ញត្តិ ស្តង់ដា វិធានការ នីតិវិធី និងការអនុវត្ត ដើម្បីគ្រប់គ្រងនិងការពារសន្តិសុខអាកាសចរស៊ីវិល ធានាសុវត្ថិភាព និរន្តរភាព និងប្រសិទ្ធភាពអាកាសចរស៊ីវិល។

**កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរស៊ីវិល** សំដៅដល់គោលការណ៍ណែនាំក្នុងការរៀបចំ តាមដាន ត្រួតពិនិត្យគ្រប់អាជ្ញាធរមានសមត្ថកិច្ចនានា ដើម្បីធានាការអនុវត្តគោលនយោបាយសន្តិសុខនិងស្តង់ដាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព និងរក្សាបានភាពប្រក្រតី។

**កម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរស៊ីវិល** សំដៅដល់គោលការណ៍ណែនាំក្នុងការបណ្តុះបណ្តាលត្រឹមត្រូវសម្រាប់អនុវត្តការងារនិងយល់ដឹងបញ្ហាសន្តិសុខ ជូនដល់កងកម្លាំងមានសមត្ថកិច្ចដែលអនុវត្តកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល។

**កម្មវិធីជាតិកិច្ចសម្រួលការដឹកជញ្ជូនតាមផ្លូវអាកាស** សំដៅដល់គោលការណ៍ណែនាំក្នុងការកាត់បន្ថយការកកស្ទះ ការបង្កើនប្រសិទ្ធភាព និងការកែលម្អសេវាអតិថិជន ឱ្យមានភាពរលូន ឆាប់រហ័ស ស្របតាមវិធាននៃការការពារសន្តិសុខសុវត្ថិភាពអាកាសចរស៊ីវិលអន្តរជាតិប្រឆាំងការប្រព្រឹត្តអំពើខុសច្បាប់ទាំងឡាយ។

**កម្មវិធីសន្តិសុខប្រតិបត្តិករ** សំដៅដល់កម្មវិធីសន្តិសុខក្រុមហ៊ុនអាកាសចរ [illegible]

អាកាសយានដ្ឋានអន្តរជាតិ អាកាសយានដ្ឋានមូលដ្ឋាន កម្មវិធីសន្តិសុខក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស និងកម្មវិធីសន្តិសុខក្រុមហ៊ុនផ្សេងៗទៀត ដែលផ្តល់សេវាកម្មនៅអាកាសយានដ្ឋាន។

ឋបនីយកណ្ឌអាកាសយានដ្ឋាន សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធ ឧបករណ៍ សម្ភារៈ បរិក្ខារបច្ចេកទេស ដែលពាក់ព័ន្ធនឹងប្រតិបត្តិការអាកាសយានដ្ឋាននិងអាកាសយាន ស្របតាមស្តង់ដាបច្ចេកទេស។

## ជំពូកទី២

## គណៈកម្មាធិការជាតិសន្តិសុខអាកាសចរស៊ីវិល

**មាត្រា៥ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិសន្តិសុខអាកាសចរស៊ីវិល ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ស.អ.**ជាសេនាធិការរាជរដ្ឋាភិបាល ទទួលបន្ទុកដឹកនាំនិងគ្រប់គ្រងការងារសន្តិសុខអាកាសចរស៊ីវិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦ .-**

**គ.ជ.ស.អ.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - អនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| - អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| - មេបញ្ជាការកងទ័ពជើងគោក | អនុប្រធាន |
| - អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| - រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| - មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| - មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |

- មេបញ្ជាការកងពលតូចលេខ៧០ សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តដែលមានអាកាសយានដ្ឋាន សមាជិក

សមាសភាពជាក់ស្តែងនៃ **គ.ជ.ស.អ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៧ .-**

**គ.ជ.ស.អ.**មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- លេខាធិការដ្ឋាននៃ**គ.ជ.ស.អ.**
- គម្រូតអាកាសយានដ្ឋានអន្តរជាតិនិងគម្រូតអាកាសយានដ្ឋានមូលដ្ឋាន
- ស្ថាប័នសម្របសម្រួលនៃ**គ.ជ.ស.អ.**
- គណៈកម្មការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ
- គណៈកម្មការសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន។

**មាត្រា៨ .-**

**គ.ជ.ស.អ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំនិងគ្រប់គ្រងលើការងារសន្តិសុខអាកាសចរស៊ីវិល នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យនិងសម្រេចលើកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរស៊ីវិល កម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរស៊ីវិលនិងកម្មវិធីជាតិកិច្ចសម្រួលការដឹកជញ្ជូនតាមផ្លូវអាកាស
- ពិនិត្យលើគោលនយោបាយជាតិ សន្ធិសញ្ញា អនុសញ្ញា ពិធីសារ អនុស្សរណៈយោគយល់ និងកិច្ចព្រមព្រៀងអន្តរជាតិនានាស្តីពីសន្តិសុខអាកាសចរស៊ីវិល ដើម្បីស្នើសុំការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល
- បែងចែកនិងប្រគល់ភារកិច្ចឱ្យកម្លាំងមានសមត្ថកិច្ចក្រោមឱវាទ និងស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តតាមកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល គោលនយោបាយជាតិ សន្ធិសញ្ញា អនុសញ្ញា ពិធីសារ អនុស្សរណៈយោគយល់ និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសន្តិសុខអាកាសចរស៊ីវិល ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា
- ត្រួតពិនិត្យការអនុវត្ត និងរក្សាឱ្យបានប្រសិទ្ធភាពកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល ដោយធ្វើការវាយតម្លៃជាប្រចាំលើវិធានការនិងបទដ្ឋានសន្តិសុខ និងវាយតម្លៃឡើងវិញ បើមានសកម្មភាពប្រព្រឹត្តបទល្មើស
- ពិនិត្យនិងសម្រេចលើការគ្រប់គ្រងតំបន់ពិសេសក្នុងបរិវេណអាកាសយានដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យនិងសម្រេចលើបទប្បញ្ញត្តិស្តីពីការផ្តល់បណ្ណចេញចូលអាកាសយានដ្ឋានសម្រាប់រថយន្តនិងសម្រាប់មន្ត្រីរាជការនៃក្រសួង ស្ថាប័ន អង្គទូត អង្គកុងស៊ុល អង្គការនានា និងភ្នាក់ងារក្រុមហ៊ុនឯកជន ដែលមានភារកិច្ចចាំបាច់
- ធ្វើការប្រជុំមួយឆមាសម្តង ហើយក្នុងករណីចាំបាច់អាចបើកប្រជុំជាវិសាមញ្ញ និងបូកសរុបសភាពការណ៍ និងសកម្មភាពការងារសន្តិសុខអាកាសចរស៊ីវិល ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។/៣/

**មាត្រា៩ ._**

ការប្រព្រឹត្តទៅរបស់ **គ.ជ.ស.អ.** មានដូចខាងក្រោម៖

- **គ.ជ.ស.អ.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន
- **គ.ជ.ស.អ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកបច្ចេកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយទាក់ទងនឹងក្របខ័ណ្ឌការងាររបស់ខ្លួន
- **គ.ជ.ស.អ.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិនានាមួយចំនួនតាមការចាំបាច់
- **គ.ជ.ស.អ.** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៣
## លេខាធិការដ្ឋាននៃគ.ជ.ស.អ.

**មាត្រា១០ ._**

**គ.ជ.ស.អ.** មានលេខាធិការដ្ឋានមួយជាសេនាធិការរដ្ឋបាល ដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី។ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ស.អ.**។

## ជំពូកទី៤
## តម្រួតអាកាសយានដ្ឋានអន្តរជាតិ
## និងតម្រួតអាកាសយានដ្ឋានមូលដ្ឋាន

**មាត្រា១១ ._**

តម្រួតអាកាសយានដ្ឋានអន្តរជាតិជាសេនាធិការនៃ**គ.ជ.ស.អ.** ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ប្រធាន |
| - មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| - អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| - អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| - មេបញ្ជាការរងនៃបញ្ជាការដ្ឋានកម្លាំងពិសេសប្រឆាំងភេរវកម្ម | សមាជិក |
| - នាយកអាកាសយានដ្ឋានអន្តរជាតិនីមួយៗ | សមាជិកប្រចាំការ។ |

សមាសភាពជាក់ស្តែងនៃតម្រួតអាកាសយានដ្ឋានអន្តរជាតិត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា១២ ._**

តម្រួតអាកាសយានដ្ឋានមូលដ្ឋានជាសេនាធិការនៃ**គ.ជ.ស.អ.** ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - តំណាងគណៈបញ្ជាការឯកភាពខេត្តដែលមានអាកាសយានដ្ឋាន | ប្រធាន |

- នាយកអាកាសយានដ្ឋានមូលដ្ឋាន អនុប្រធានប្រចាំការ
- តំណាងស្នងការដ្ឋាននគរបាលខេត្តដែលមានអាកាសយានដ្ឋាន សមាជិក
- តំណាងកងរាជអាវុធហត្ថខេត្តដែលមានអាកាសយានដ្ឋាន សមាជិក។

សមាសភាពជាក់ស្តែងនៃគម្រូតអាកាសយានដ្ឋានមូលដ្ឋានត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ស.អ.**។

**មាត្រា១៣ .-**

គម្រូតអាកាសយានដ្ឋានអន្តរជាតិនិងគម្រូតអាកាសយានដ្ឋានមូលដ្ឋានមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យរាល់សកម្មភាពនិងប្រតិបត្តិការនៃមន្ត្រីមានសមត្ថកិច្ចនិងភ្នាក់ងារទាំងអស់ដែលបម្រើការនៅក្នុងអាកាសយានដ្ឋានអន្តរជាតិនិងអាកាសយានដ្ឋានមូលដ្ឋាន
- ធ្វើរបាយការណ៍អំពីសភាពការណ៍និងសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូន**គ.ជ.ស.អ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន**គ.ជ.ស.អ.** ប្រគល់ជូន។

## ជំពូកទី៥

## ស្ថាប័នសម្របសម្រួលនៃ គ.ជ.ស.អ.

**មាត្រា១៤ .-**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាស្ថាប័នសម្របសម្រួលការងារបច្ចេកទេសដែលមានតួនាទីនិងភារកិច្ចបន្ថែមដូចខាងក្រោម៖

- រៀបចំ ចងក្រង និងកែសម្រួលលើកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរស៊ីវិល កម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរស៊ីវិល និងកម្មវិធីជាតិកិច្ចសម្រួលការដឹកជញ្ជូនតាមផ្លូវអាកាស
- ពិនិត្យសម្រេចលើកម្មវិធីសន្តិសុខប្រតិបត្តិករ
- សម្របសម្រួលជាមួយអង្គការអាកាសចរស៊ីវិលអន្តរជាតិលើការងារសន្តិសុខអាកាសចរស៊ីវិល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន**គ.ជ.ស.អ.** ប្រគល់ជូន។

## ជំពូកទី៦

## គណៈកម្មការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ

**មាត្រា១៥ .-**

គណៈកម្មការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ ដែលសរសេរជាអក្សរកាត់ថា**គ.ស.អ.អ.** ជាអង្គភាពប្រតិបត្តិ ស្ថិតក្រោមការដឹកនាំនិងគ្រប់គ្រងផ្ទាល់របស់**គ.ជ.ស.អ.** និងមានសមាភាពដូចខាងក្រោម៖

- នាយកអាកាសយានដ្ឋានអន្តរជាតិនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ ប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ

- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ — អនុប្រធាន
- តំណាងនាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិលនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល — អនុប្រធាន
- តំណាងសាលារាជធានី ខេត្ត ដែលមានអាកាសយានដ្ឋានអន្តរជាតិ — អនុប្រធាន
- តំណាងបញ្ជាការដ្ឋានកងទ័ពជើងអាកាស — អនុប្រធាន
- តំណាងកងពលតូចលេខ៧០ — អនុប្រធាន
- ប្រធានការិយាល័យសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ — អនុប្រធានប្រចាំការ
- តំណាងក្រសួងសុខាភិបាល — សមាជិក
- តំណាងបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម — សមាជិក
- តំណាងបញ្ជាការដ្ឋានកងទ័ពជើងទឹក — សមាជិក
- តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស — សមាជិក
- តំណាងអគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម ប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ — សមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ — សមាជិក
- តំណាងអង្គភាពតម្រួតបទបញ្ជានៃអគ្គស្នងការនគរបាលជាតិ ប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ — សមាជិក
- តំណាងក្រុមហ៊ុនអាកាសចរជាតិ — សមាជិក
- តំណាងក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស — សមាជិក
- តំណាងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន — សមាជិក

សមាសភាពជាក់ស្តែងនៃ**គ.ស.អ.អ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន**គ.ជ.ស.អ.**។

**មាត្រា១៦ .-**

**គ.ស.អ.អ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំនិងគ្រប់គ្រងលើការងារសន្តិសុខអាកាសចរស៊ីវិល នៅក្នុងនិងនៅជុំវិញអាកាសយានដ្ឋានអន្តរជាតិ
- អនុវត្តនិងសម្របសម្រួលលើការងារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងនិងនៅជុំវិញអាកាសយានដ្ឋានអន្តរជាតិ ឱ្យស្របតាមកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល និងកម្មវិធីសន្តិសុខប្រតិបត្តិករ
- ត្រួតពិនិត្យនិងតាមដានលើការអនុវត្តកម្មវិធីសន្តិសុខរបស់ប្រតិបត្តិករ រួមទាំងវិធានការសន្តិសុខពិសេសៗដែលស្នើឡើងដោយប្រតិបត្តិករ
- ផ្សព្វផ្សាយកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល កម្មវិធីសន្តិសុខប្រតិបត្តិករនិងកម្មវិធីសន្តិសុខពាក់ព័ន្ធផ្សេងៗ ដល់បណ្តាសមត្ថកិច្ចនិងស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្ត

- ធានានូវវិធានការអប្បបរមានិងបទដ្ឋាននានា ដើម្បីឆ្លើយតបនឹងការគំរាមកំហែង និងត្រួតពិនិត្យជាប្រចាំ ដែលអាចធានាបានទាំងស្ថានភាពធម្មតាទាំងស្ថានភាពភាពអាសន្ន
- សហការជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន ដើម្បីកំណត់ផែនទីតំបន់ធ្វើសកម្មភាព និង តំបន់ហាមឃាត់នៅក្នុងអាកាសយានដ្ឋានអន្តរជាតិ
- កំណត់ផែនទីគោលដៅសន្តិសុខ ចាត់តាំងកម្លាំងឈរជើង និងពិនិត្យលើការបំពាក់ឧបករណ៍សម្ភារៈឱ្យគ្រប់គ្រាន់ សម្រាប់បម្រើឱ្យការងារសន្តិសុខនៅក្នុងបរិវេណអាកាសយានដ្ឋានអន្តរជាតិ
- សហការរៀបចំការអនុវត្តកម្មវិធីត្រួតពិនិត្យគុណភាពសន្តិសុខនៅអាកាសយានដ្ឋានអន្តរជាតិ រួមមាន ការបណ្ដុះបណ្ដាល ការវាយតម្លៃ សវនកម្ម អធិការកិច្ច ការសាកល្បង និងការអង្កេតតាមកម្មវិធី ព្រមទាំងការអង្កេតក្នុងករណីចាំបាច់
- សហការនិងចូលរួមផ្ដល់យោបល់លើការបញ្ចូលវិធានការសន្តិសុខទៅក្នុងគម្រោងកែលម្អ និងអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិ
- រៀបចំឲ្យមានសកម្មភាពល្បាត ត្រួតពិនិត្យជាចំហ ដើម្បីទប់ស្កាត់អំពើភេរវកម្មនិងសកម្មភាពល្មើសច្បាប់ផ្សេងៗទៀត
- ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន**គ.ជ.ស.អ.**
- រៀបចំកិច្ចប្រជុំយ៉ាងតិចមួយខែម្ដង និងក្នុងករណីចាំបាច់ ត្រូវកោះប្រជុំជាវិសាមញ្ញ
- បូកសរុបរបាយការណ៍អំពីសភាពការណ៍ និងសកម្មភាពការងារនៅអាកាសយានដ្ឋានអន្តរជាតិប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូនប្រធាន**គ.ជ.ស.អ.** ដើម្បីជ្រាប និងផ្ដល់ការណែនាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន**គ.ជ.ស.អ.** ប្រគល់ជូន។

**មាត្រា១៧ .-**

**គ.ស.អ.អ.** មានសិទ្ធិប្រើត្រាដោយឡែកនិងប្រើសញ្ញារបស់រាជរដ្ឋាភិបាល។ **គ.ស.អ.អ.** មានទីតាំងនៅអាកាសយានដ្ឋានអន្តរជាតិនីមួយៗ។

## ជំពូកទី៧

## គណៈកម្មការសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន

**មាត្រា១៨ .-**

គណៈកម្មការសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន ដែលសរសេរជាអក្សរកាត់ថា**គ.ស.អ.ម.** ជាអង្គភាពស្ថិតក្រោមការដឹកនាំនិងគ្រប់គ្រងផ្ទាល់ពី**គ.ជ.ស.អ.** និងមានសមាសភាពដូចខាងក្រោម៖

- នាយកអាកាសយានដ្ឋានមូលដ្ឋាននៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធាន
- តំណាងសាលាខេត្តដែលមានអាកាសយានដ្ឋាន អនុប្រធាន
- ប្រធានសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាននីមួយៗ អនុប្រធាន

- តំណាងស្នងការដ្ឋាននគរបាលខេត្តដែលមានអាកាសយានដ្ឋាន សមាជិក
- តំណាងបញ្ជាការដ្ឋានកងទ័ពជើងអាកាស សមាជិក
- តំណាងបញ្ជាការដ្ឋានយោធភូមិភាគ សមាជិក
- តំណាងកងរាជអាវុធហត្ថខេត្តដែលមានអាកាសយានដ្ឋាន សមាជិក
- តំណាងតំបន់ប្រតិបត្តិការសឹករងខេត្តដែលមានអាកាសយានដ្ឋាន សមាជិក
- តំណាងក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស សមាជិក

សមាសភាពជាក់ស្តែងនៃ **គ.ស.អ.ម.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន**គ.ជ.ស.អ.** ។

**មាត្រា១៩ .-**

**គ.ស.អ.ម.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំនិងគ្រប់គ្រងលើការងារសន្តិសុខអាកាសចរស៊ីវិលនៅក្នុងនិងនៅជុំវិញអាកាសយានដ្ឋានមូលដ្ឋាន
- រៀបចំ ចងក្រង អនុវត្ត និងកែសម្រួលសេចក្តីព្រាងកម្មវិធីសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន ដើម្បីដាក់ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលពិនិត្យនិងសម្រេច
- អនុវត្តនិងសម្របសម្រួលលើការងារ សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងនិងនៅជុំវិញអាកាសយានដ្ឋានមូលដ្ឋាន ឱ្យស្របតាមកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល និងកម្មវិធីសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន
- ផ្សព្វផ្សាយកម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិលនិងកម្មវិធីសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន ដល់បណ្តាសមត្ថកិច្ចនិងស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្ត
- ធានាវិធានការអប្បបរមានិងបទដ្ឋាននានា ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែង និងត្រួតពិនិត្យជាប្រចាំ ដើម្បីធានាបានទាំងស្ថានភាពធម្មតាទាំងស្ថានភាពភាពអាសន្ន
- កំណត់ដែនទីតំបន់ហាមឃាត់ តំបន់ធ្វើសកម្មភាព និងចាត់តាំងកម្លាំងឈរជើងនៅក្នុងបរិវេណអាកាសយានដ្ឋានមូលដ្ឋាន
- សហការនិងចូលរួមផ្តល់យោបល់លើការបញ្ចូលវិធានការសន្តិសុខ ទៅក្នុងគម្រោងអភិវឌ្ឍន៍អាកាសយានដ្ឋានមូលដ្ឋាន
- រៀបចំកិច្ចប្រជុំយ៉ាងតិចមួយខែម្តង និងក្នុងករណីចាំបាច់ ត្រូវកោះប្រជុំជាវិសាមញ្ញ
- បូកសរុបរបាយការណ៍អំពីសភាពការណ៍និងសកម្មភាពការងារនៅអាកាសយានដ្ឋានមូលដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនប្រធាន**គ.ជ.ស.អ.** ដើម្បីជ្រាបនិងផ្តល់ការណែនាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន**គ.ជ.ស.អ.** ប្រគល់ជូន។

## ជំពូកទី៨
## សមត្ថកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា២០ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមី ដែលមានអាកាសយានដ្ឋានអន្តរជាតិនិងអាកាសយានដ្ឋានមូលដ្ឋាន មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ទទួលអនុវត្តច្បាប់និងបទបញ្ជារបស់រាជរដ្ឋាភិបាល ព្រមទាំងបទបញ្ជារបស់**គ.ជ.ស.អ.** ស្តីពីសកម្មភាពការងារដែលពាក់ព័ន្ធនឹងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិនិងអាកាសយានដ្ឋានមូលដ្ឋាន
- បង្ការទប់ស្កាត់និងលុបបំបាត់នូវក្រុមនិងសំណង់អនាធិបតេយ្យ នៅជាប់ជុំវិញអាកាសយានដ្ឋានអន្តរជាតិនិងអាកាសយានដ្ឋានមូលដ្ឋានដែលស្ថិតក្រោមការគ្រប់គ្រងនិងសមត្ថកិច្ចរបស់ខ្លួន
- ធានានិងការពារសន្តិសុខ សុវត្ថិភាពដល់អាកាសយាន អ្នកដំណើរ និងអីវ៉ាន់ ក្នុងករណីចុះចតបន្ទាន់ឬមានឧប្បត្តិហេតុស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៩
## កញ្ចប់ថវិកានៃ គ.ជ.ស.អ

**មាត្រា២១ .-**

ប្រភពថវិកាចំណាយសម្រាប់ដំណើរការរបស់**គ.ជ.ស.អ.**៖

- ថវិកាជាតិក្នុងគម្រោងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ការឧបត្ថម្ភពីប្រភពផ្សេងៗ។

## ជំពូកទី១០
## យន្តការអន្តរាគមន៍

**មាត្រា២២ .-**

កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដែលមានទីតាំងនៅជិតអាកាសយានដ្ឋានអន្តរជាតិនិងអាកាសយានដ្ឋានមូលដ្ឋាន ត្រូវចេញធ្វើអន្តរាគមន៍ជាបន្ទាន់តាមតួនាទីនិងភារកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងអង្គភាពសាមី ក្នុងពេលដែលមានសំណូមពរពីប្រធាន**គ.ជ.ស.អ.**។

ក្នុងករណីមានកើតជំងឺឆ្លងរាលដាលក្នុងផ្ទៃប្រទេសនិងអន្តរជាតិ មានគ្រោះមហន្តរាយធ្ងន់ធ្ងរកើតឡើង រាជរដ្ឋាភិបាលនឹងត្រូវពេញបរិទេសបញ្ជាឱ្យមន្ត្រី ភ្នាក់ងារ និងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទនៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចេញធ្វើអន្តរាគមន៍បំពេញបេសកកម្មនៅអាកាសយានដ្ឋានអន្តរជាតិនិងអាកាសយានដ្ឋានមូលដ្ឋាន តាមករណីជាក់ស្តែងនីមួយៗ។

## ជំពូកទី១១
## ទោសប្បញ្ញត្តិ

**មាត្រា២៣ .-**

កម្លាំងនិងមន្ត្រីភ្នាក់ងារមានសមត្ថកិច្ចនៃក្រសួង ស្ថាប័ន និងអង្គភាពដែលបានចាត់បញ្ជូនមកឱ្យប្រចាំការ ឬបំពេញបេសកកម្មការងារនៅក្នុងអាកាសយានដ្ឋានអន្តរជាតិនិងអាកាសយានដ្ឋានមូលដ្ឋាន ដែលបានឆ្លៀតប្រើប្រាស់តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនបង្កឱ្យមានការលំបាកដល់អ្នកដំណើរនិងការឆ្លងកាត់ទំនិញគ្រប់ប្រភេទនៃប្រតិបត្តិការអាកាសយានរបស់ក្រុមហ៊ុនអាកាសចរនានា និងប្រតិបត្តិការអាកាសយានដ្ឋានអន្តរជាតិនិងអាកាសយានដ្ឋានមូលដ្ឋាន ដោយគ្មានមូលហេតុស្របច្បាប់ឬរំលោភបំពានសមត្ថកិច្ចនៃ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា២៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

រចនាសម្ព័ន្ធគណៈកម្មាធិការជាតិសន្តិសុខអាកាសចរស៊ីវិល
ជាឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២១២ អនក្រ.បក ចុះថ្ងៃទី
១៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងសន្តិសុខអាកាស
ចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ២១៣. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី
## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់
## ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩១៣ /៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១២១៣ /១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រែប្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែល ប្រកាសឲ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកប /០៨០៦ /៣៣៩ ចុះថ្ងៃទី០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពី គោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់ក្រសួងមហាផ្ទៃ
- តាមសំណើ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**សម្រេច**

**មាត្រា ១** :-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងដូចខាងក្រោម៖

-ដីអតីតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានដីទំហំ ៣៧.៥០០ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ ៧០ ជាប់ខាងលិចរបងស្ពានចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-ដីមួយផ្នែករបស់សាលាស្រុកសន្ទុក មានទំហំ ៩៧៧ ម៉ែត្រក្រឡា ស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៦ ក្នុងភូមិធម្មនាថ ឃុំតាំងក្រសាំង ស្រុកសន្ទុកខេត្តកំពង់ធំ។

**មាត្រា ២** :-

ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធី ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងមហាផ្ទៃ។

**មាត្រា ៣** :-

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤** :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧២១៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៦៥អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១._**

ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៧០ ២៧០ ០០០ ០០០រៀល (ចិតសិបពាន់ពីររយចិតសិបលានរៀលគត់) ពីជំពូក៦៥ (ឧបត្ថម្ភកធននិងជំនួយសង្គម-ឧបត្ថម្ភកធនរាជធានី ខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់) នៃខ្ទង់កំណាយមិនទាន់បែងចែក មកជំពូក៦៥ (ឧបត្ថម្ភកធននិងជំនួយសង្គម-ឧបត្ថម្ភរាជធានី ខេត្ត) ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភរាជធានី ខេត្ត ក្នុងឆ្នាំ២០១៤។

**មាត្រា៣._**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតវិទ្យាស្ថានស្លឹករឹត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយដែលមានឈ្មោះថា វិទ្យាស្ថានស្លឹករឹត SLEUK RITH INSTITUTE សរសេរជាអក្សរកាត់ជាភាសាខ្មែរ វ.ស.រ. និងជាភាសាអង់គ្លេស S.R.I.។

**មាត្រា២ .-**

វិទ្យាស្ថានស្លឹករឹត មានទីតាំងស្ថិតនៅក្នុងបរិវេណវិទ្យាល័យបឹងត្របែក មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ វិទ្យាស្ថាននេះស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ទៅអនាគត វិទ្យាស្ថាននេះអាចសុំប្តូរឈ្មោះថ្មីឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ .-**

វិទ្យាស្ថានស្លឹករឹតមានផ្នែកសំខាន់ៗដូចខាងក្រោម៖

- សារមន្ទីរ
- មជ្ឈមណ្ឌលស្រាវជ្រាវ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវលើមុខជំនាញឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ វិវាទកម្ម និងសិទ្ធិមនុស្ស ដោយធ្វើការបណ្តុះបណ្តាលគ្រប់កម្រិតឧត្តមសិក្សាលើមុខជំនាញទាំងនេះ
- មជ្ឈមណ្ឌលសារព័ត៌មាន។

**មាត្រា៤ .-**

វិទ្យាស្ថានស្លឹករឹត ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

**មាត្រា៥ .-**

នាយកវិទ្យាស្ថានស្លឹករឹតមានភារកិច្ច៖

- អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំផ្ទៃក្នុងនៅឧត្តមសិក្សា
- រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន និងវិធានផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងការសិក្សាឱ្យបានច្បាស់លាស់
- ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតតាមមុខជំនាញ ដើម្បីស្នើសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ដំណើរការបណ្តុះបណ្តាល
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំមកអគ្គនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា
- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានស្លឹករឹត។

**មាត្រា៦ ._**

និស្សិតឬអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ ដែលបានរៀនចប់តាមកម្មវិធីសិក្សា និងស្រាវជ្រាវ ហើយទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រឬវិញ្ញាបនបត្រ តាមមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះផ្តល់ឱ្យដោយវិទ្យាស្ថានស្លឹករឹត ក្នុងករណីវិទ្យាស្ថានស្លឹករឹតបំពេញនិងអនុវត្តបានតាមគោលការណ៍និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧៥៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្ដីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកប្រាសាទបល្ល័ង្គ នៃខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ២៤៨/១៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី២
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកប្រាសាទបល្ល័ង្គ នៃខេត្តកំពង់ធំ ក្នុងអាណត្តិទី២ ដូចមានរាយនាមខាងក្រោមៈ

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | លោក **គីម អាន** | ១០-០១-១៩៥២ | ជាប្រធានក្រុមប្រឹក្សាស្រុក |
| ២- | លោក **ឈួន រ៉ា** | ២៩-១១-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៣- | លោក **សេង សារ៉ាត់** | ២៨-០៤-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |

| | | | |
|---|---|---|---|
| ៤- | លោក **អ៊ុំ អ៊ិត** | ០៩-១០-១៩៦០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៥- | លោកស្រី **ហ៊ល ល្មៀង** | ១៥-០៤-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៦- | លោក **អិន ហ៊ង** | ១៥-០៣-១៩៥៦ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៧- | លោក **ពេជ្រ គី** | ០៩-១១-១៩៥២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៨- | លោក **កុយ ខន** | ១៩-០៣-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៩- | លោក **ទុយ សុធារិទ្ធ** | ០២-០២-១៩៦៣ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១០- | លោក **ឈាំ សាព** | ១១-១២-១៩៦៩ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១១- | លោក **អ៊ុក ថន** | ០៤-០៩-១៩៦៩ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១២- | លោក **អ៊ំ ស៊ើ** | ០១-០៤-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៣- | លោកស្រី **ហាង់ ជាង** | ១៥-០២-១៩៧៦ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៤- | លោក **ឡុង និន** | ១៩៦០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៥- | លោក **ឃុំ សុខ** | ០៧-០៤-១៩៥៨ | ជាសមាជិកក្រុមប្រឹក្សាស្រុក។ |

**មាត្រា ២.—**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.—**

ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកប្រាសាទបល្ល័ង្គ នៃខេត្តកំពង់ធំ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤.—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានី[illegible] ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ២៤៨/១៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី២
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ ក្នុងអាណត្តិទី២ ដូចមានរាយនាមខាងក្រោម:

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | លោក **គឹម សួរ** | ០១-០១-១៩៤៨ | ជាប្រធានក្រុមប្រឹក្សាក្រុង |
| ២- | លោក **ស្រី ស្រៀង** | ២៩-១០-១៩៥២ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ៣- | លោកស្រី **ខ្លូត សារី** | ០២-០៤-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាក្រុង |

| | | | |
|---|---|---|---|
| ៤- | លោក **ឡេង សារិត** | ០១-១២-១៩៤៧ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ៥- | លោក **សាប់ សាំងអ៊ាង** | ០៣-០៤-១៩៤៦ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ៦- | លោក **ទ៉ាន់ ថន** | ១១-០៩-១៩៤៩ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ៧- | លោក **អាន សំរោត** | ១៥-០៧-១៩៤៤ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ៨- | លោក **យិន ឡើន** | ២២-០១-១៩៤៥ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ៩- | លោក **អ៊ុត សៃរេម** | ០១-០១-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ១០- | លោក **ម៉ឹង សុខុម** | ០១-០៥-១៩៥១ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ១១- | លោក **យក់ រឿន** | ០២-១០-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ១២- | លោកស្រី **ម៉ឹង មូរី** | ០៥-០២-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ១៣- | លោក **យូ យិន** | ០១-០៧-១៩៨១ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ១៤- | លោក **សេង វណ្ណា** | ០៣-០៥-១៩៧៣ | ជាសមាជិកក្រុមប្រឹក្សាក្រុង |
| ១៥- | លោកស្រី **សេង គឹមស្រ៊ុន** | ០៥-០៧-១៩៦០ | ជាសមាជិកក្រុមប្រឹក្សាក្រុង។ |

**មាត្រា ២.-**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
  អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៣៤៦...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកស្ទោង នៃខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ២៤៨/១៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី២
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកស្ទោង នៃខេត្តកំពង់ធំ ក្នុងអាណត្តិទី២ ដូចមានរាយនាមខាងក្រោម:

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | លោក **ឌូ គឹមហ៊ុន** | ១៤-១០-១៩៥៥ | ជាប្រធានក្រុមប្រឹក្សាស្រុក |
| ២- | លោកស្រី **មូល ឡុន** | ០៥-០៥-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៣- | លោក **ទ្រាំ សោន** | ០៥-០២-១៩៥១ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៤- | លោក **ពន ម៉េង** | ០១-១១-១៩៤០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |

| | | | |
|---|---|---|---|
| ៥- | លោក **ស៊ិន សុម៉ាលី** | ១៨-០៨-១៩៥២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៦- | លោកស្រី **ម៉ែន គីមយ៉េត** | ១០-០៩-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៧- | លោក **ចោង ជា** | ១៤-០៤-១៩៤៨ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៨- | លោក **ទូ គុណថេង** | ១០-០៩-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៩- | លោកស្រី **នូ មាលតី** | ១២-០២-១៩៨២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១០- | លោក **ឡាយ ហឿង** | ១២-០២-១៩៥២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១១- | លោក **លឹម នៃហេង** | ១១-០២-១៩៥០ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១២- | លោក **មិត សាឡាង** | ១៧-០៤-១៩៥១ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៣- | លោក **សាំង ហ៊ី** | ០៩-០៩-១៩៥១ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៤- | លោក **ចាន់ ថន** | ០៦-០៨-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៥- | លោក **ឆាយ ចែង** | ០២-០២-១៩៨១ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៦- | លោក **ឌុច ហូ** | ០៣-០៤-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៧- | លោក **សូ សុខ** | ១២-១២-១៩៦៦ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៨- | លោកស្រី **គី ឆេងថន** | ០៧-០៥-១៩៥៦ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៩- | លោក **ពេជ្រ ម៉ក់** | ១៣-០៣-១៩៥៣ | ជាសមាជិកក្រុមប្រឹក្សាស្រុក។ |

**មាត្រា ២.-**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.-**

ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកស្ទោង នៃខេត្តកំពង់ធំ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៦ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧៣៤ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកប្រាសាទសំបូរ នៃខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ២៤៨/១៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី២
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកប្រាសាទសំបូរ នៃខេត្តកំពង់ធំ ក្នុងអាណត្តិទី២ ដូចមានរាយនាមខាងក្រោម:

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | លោក **ភុច ស៊ីនហូ** | ០៤-១១-១៩៥២ | ជាប្រធានក្រុមប្រឹក្សាស្រុក |
| ២- | លោក **អ៊ុំ គីមអាន** | ១០-០៥-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៣- | លោកស្រី **ស គីមសាក់** | ១៥-០១-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |

| | | | |
|---|---|---|---|
| ៤- | លោក **ឃី លឹមជាង** | ១៩-១០-១៩៥៦ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៥- | លោក **រស់ ផន** | ០៣-០៩-១៩៥២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៦- | លោក **សេង លីហួង** | ០១-០១-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៧- | លោក **ទី ខ្មែរអាង** | ០២-០៤-១៩៥២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៨- | លោក **ភឹម សៀត** | ០១-០១-១៩៤៩ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ៩- | លោក **ខេ ហេង** | ០១-០៨-១៩៤៦ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១០- | លោក **ឌ៉ុយ ទ្រី** | ១០-០៥-១៩៤៥ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១១- | លោក **សុខ ខេង** | ១៥-០៣-១៩៥៦ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១២- | លោក **ម៉ីន សុភា** | ០៧-០៨-១៩៦៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៣- | លោក **ឆិន អ៊ឹម** | ០៣-០៤-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៤- | លោក **ហម ណារិទ្ធិ** | ៣០-០៥-១៩៧២ | ជាសមាជិកក្រុមប្រឹក្សាស្រុក |
| ១៥- | លោកស្រី **លឿង គឹមហ៊ាន** | ១៩៦២ | ជាសមាជិកក្រុមប្រឹក្សាស្រុក ។ |

**មាត្រា ២.–**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.–**

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ២១២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់

# សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិសន្តិសុខអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម **ឱម យ៉ិនទៀង** | ទេសរដ្ឋមន្ត្រី អនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម | អនុប្រធាន |
| ៣- | ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- | ឯកឧត្តមនាយឧត្តមសេនីយ៍ **ឯល ម៉ាន់សារ៉ាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៥- | ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ុល សារឿន** | អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| ៦- | ឯកឧត្តមនាយឧត្តមសេនីយ៍ **មាស សុផា** | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក | អនុប្រធាន |
| ៧- | ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| ៨- | ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៩- | ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធានប្រចាំការ |
| ១០- | ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១- | ឯកឧត្តម **ទី តាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២- | ឯកឧត្តម **ជា ម្៉ូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៣- | ឯកឧត្តម **ឱម គីមស៊ា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤- | ឯកឧត្តម **គឹម ស៊ីថន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៥- | ឯកឧត្តម **អេង ហួត** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៦- | ឯកឧត្តម **ព្រហ្ម សិទ្ធត្រា** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៧- | លោកជំទាវ **មឹន មាណាវី** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៨- | ឯកឧត្តមនាយឧត្តមសេនីយ៍ **សុខ ផល** | អគ្គនាយកនៃអគ្គនាយដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៩- | ឯកឧត្តមនាយឧត្តមសេនីយ៍ **ស៊ឹង សំណាង** | មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| ២០- | ឯកឧត្តមនាយឧត្តមនាវី **ទៀ វិញ** | មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |
| ២១- | ឯកឧត្តម **ឡាំ ហេងហួត** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ២២- | ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ៅ សុផាន់** | នាយរងសេនាធិការចម្រុះ និងជាមេបញ្ជាការកងពលតូចលេខ៧០ | សមាជិក |

| | | | |
|---|---|---|---|
| ២៣- | ឯកឧត្តម **ប៉ា សុជាតិវង្ស** | អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ២៤- | ឯកឧត្តម **ឃឹម ប៊ុនសុង** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ២៥- | ឯកឧត្តម **ឈិត សុខុន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន ក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៨.សសរ.

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគម្រួតអាកាសយានដ្ឋានអន្តរជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ២១២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ១១៧ សសរ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិសន្តិសុខអាកាសចរស៊ីវិល
- យោងតាមតម្រូវការចាំបាច់

## **សម្រេច**

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគម្រួតអាកាសយានដ្ឋានអន្តរជាតិ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សយ សុខាន់** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ប្រធាន |
| ២- | ឯកឧត្តមឧត្តមសេនីយ៍ទោ **ជា សំណាង** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៣- | ឯកឧត្តមឧត្តមសេនីយ៍ឯក **គៀត ចន្ទ័ថារិទ្ធិ** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តមឧត្តមសេនីយ៍ឯក **ឃុន សំបូរ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ៥- | ឯកឧត្តម **ម៉ិន រដ្ឋា** | នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | សមាជិកប្រចាំការ |
| ៦- | ឯកឧត្តម **តិត្យ ចន្ថា** | នាយកអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប | សមាជិកប្រចាំការ |
| ៧- | លោក **ហ៊ុន ឈឿន** | នាយកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ | សមាជិកប្រចាំការ |
| ៨- | លោកវរសេនីយ៍ឯក **ម៉ឺន មករា** | មេបញ្ជាការរងកងកម្លាំងពិសេសប្រឆាំងភេរវកម្ម | សមាជិក |

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន ក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ៦៦៤.......សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់អាករនាំចេញជាបន្ទុករបស់រដ្ឋលើមុខទំនិញមួយចំនួន

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ២៨១ សហវ.ប្រក.អគរ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០១២
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

**សម្រេច**

**ប្រការ ១.-**

ត្រូវបានដាក់អាករនាំចេញជាបន្ទុករបស់រដ្ឋ លើមុខទំនិញកម្ទេចឬចំណាំងឈើ (Wood in Chips or Particles) អាចម៍រណា (Sawdust) ព្រមទាំងកម្ទេចឈើ (Chipwood) ផ្សេងទៀតដែលមានលេខកូដសម្គាល់ ៤៤០១.២១.០០ ៤៤០១.២២.០០ ៤៤០១.៣១.០០ និង ៤៤០៤.២០.១០ នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១២ ដែលផលិតឬកែច្នៃចេញពីឈើដាំក្នុងស្រុកដូចជា ដើមអាកាស្យា និងដើមប្រេងខ្យល់ ជាដើម។

អាករនាំចេញដូចមានចែងក្នុងកថាខណ្ឌទី១នៃប្រការនេះ ដែលរដ្ឋទទួលបន្ទុក ត្រូវបានកត់ត្រាជាចំណូលនៃថវិកាប្រចាំខែរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងអនុគណនីចំណូលថវិកាលេខ ៧១១១ ហើយត្រូវកត់ត្រាក្នុងចំណាយជាអន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលនិងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវចាត់ចែង និងអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.[illegible].....សហវ.ប្រក

# ប្រកាស

## ស្ដីពី

## ការដាក់អាករនាំចេញជាបន្ទុករបស់រដ្ឋលើមុខទំនិញជាផលិតផលវារីវប្បកម្ម

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ៤៨១ សហវ.ប្រក.អគរ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០១២
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់អាករនាំចេញជាបន្ទុករបស់រដ្ឋ លើមុខទំនិញផលិតផលជលផលដែលទទួលបានពីសកម្មភាពវារីវប្បកម្ម (Aquaculture) ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានលេខកូដសម្គាល់នានាក្នុងជំពូកទី៣ នៃតារាងពន្ធគយកម្ពុជាឆ្នាំ២០១២ និងដែលមានការទទួលស្គាល់ពីអង្គភាពជំនាញមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមបទប្បញ្ញត្តិជាធរមាន។

អាករនាំចេញដូចមានចែងក្នុងកថាខណ្ឌទី១នៃប្រការនេះ ដែលរដ្ឋទទួលបន្ទុក ត្រូវបានកត់ត្រាជាចំណូលនៃថវិកាប្រចាំខែរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងអនុគណនីចំណូលថវិកាលេខ ៧១១៤ ហើយត្រូវកត់ត្រាក្នុងចំណាយជាអន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលនិងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវចាត់ចែង និងអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ ១៣៣ ប្រក

**ប្រកាស**
**ស្តីពី**
**ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័នក្រសួងនិងសហគ្រាសសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សម្រេច**

**ជំពូកទី ១**
**បទប្បញ្ញត្តិទូទៅ**

**ប្រការ ១ .-**

ប្រកាសនេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ២ ._**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម ៖

- រៀបចំបេសកកម្ម និងវេទនាសម្ព័ន្ធរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- រៀបចំមុខងារ និងភារកិច្ចរបស់ការិយាល័យនានានៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

**ប្រការ ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ការិយាល័យ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដោយគ្របដណ្តប់លើការងារសវនកម្មផ្ទៃក្នុង។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**ប្រការ ៤ ._**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើការងារពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

បេសកកម្មនេះធ្វើឡើងតាមរយៈការរៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈ និងលិខិតបទដ្ឋានទាំងឡាយដែលទាក់ទងទៅនឹងមុខងារសវនកម្មផ្ទៃក្នុង។

**ប្រការ ៥ ._**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានភារកិច្ចអនុវត្តស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ ៤០អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ។

ក្រៅពីបទប្បញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌខាងលើនេះ នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានភារកិច្ចផ្សេងទៀតដូចខាងក្រោម ៖

- ត្រួតពិនិត្យផ្ទៃក្នុង ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួង
- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម និងផែនការសវនកម្មប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច
- តាមដានដំណើរការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង
- សម្របសម្រួលការងារជាមួយសមត្ថកិច្ចត្រួតពិនិត្យនានា
- ចូលរួមរៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលទាក់ទងនឹងការងារសវនកម្ម
- រាយការណ៍ និង/ឬធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង និងធ្វើរបាយការណ៍ជូនអាជ្ញាធរសវនកម្មជាតិ
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន

- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលក្រសួងប្រគល់ជូន។

**ប្រការ ៦.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានការិយាល័យចំណុះចំនួនប្រាំគឺ ៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យសវនកម្មទី១
- ការិយាល័យសវនកម្មទី២
- ការិយាល័យសវនកម្មទី៣
- ការិយាល័យសវនកម្មទី៤

**ប្រការ ៧.-**

ការិយាល័យនីមួយៗរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

អង្គការលេខរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៣
## តួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗ

**ប្រការ ៨.-**

ការិយាល័យរដ្ឋបាលមានភារកិច្ច ៖

- សម្របសម្រួលរាល់សកម្មភាពការងាររបស់នាយកដ្ឋាន
- គ្រប់គ្រង ចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗ
- រក្សាទុកដាក់របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធ
- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម និងផែនការសវនកម្មប្រចាំឆ្នាំ ដោយសហការជាមួយនឹងការិយាល័យសវនកម្ម
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់នាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់នាយកដ្ឋាន
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងនាយកដ្ឋាន
- សរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៩ .-**

ការិយាល័យសវនកម្មទី១ ទទួលខុសត្រូវការងារសវនកម្មតាមនាយកដ្ឋាន និងអង្គភាពនានាចំណុះឲ្យអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ និងអគ្គាធិការដ្ឋាន។

ការិយាល័យសវនកម្មទី២ ទទួលខុសត្រូវការងារសវនកម្មតាមនាយកដ្ឋាន និងអង្គភាពនានាចំណុះឲ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងវិទ្យាស្ថានប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ការិយាល័យសវនកម្មទី៣ ទទួលខុសត្រូវការងារសវនកម្មតាមមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី។

ការិយាល័យសវនកម្មទី៤ ទទួលខុសត្រូវការងារសវនកម្មតាមមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្ដរមានជ័យ ខេត្តព្រះវិហារ ខេត្តសៀមរាប និងខេត្តកំពង់ធំ។

**ប្រការ ១០ .-**

ការិយាល័យសវនកម្មនីមួយៗមានភារកិច្ចដូចខាងក្រោម ៖

- សហការជាមួយការិយាល័យរដ្ឋបាល ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម ផែនការសវនកម្មប្រចាំឆ្នាំ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋានជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច
- ពិនិត្យឡើងវិញលើមុខងារ សកម្មភាព ប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពនានា ក្នុងការិយបរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធី នៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព
- កំណត់នូវភាពសមស្រប គ្រប់គ្រាន់ និងការផ្ដល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្នែកគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការរបស់អង្គភាព
- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុ និងប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលបានប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណវាស់វែងចំណាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មានទាំងនោះ
- ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើត ដើម្បីធានាបានទៅតាមគោលនយោបាយ ផែនការនីតិវិធីច្បាប់ បទបញ្ញាទាំងឡាយដែលមានឥទ្ធិពលសំខាន់លើប្រតិបត្តិការ និងរបាយការណ៍។ ក្នុងករណីអង្គភាពអនុវត្តពុំបានសមស្របដូចរៀបរាប់ខាងលើ ចាំបាច់សំណូមពរឱ្យមានការផ្លាស់ប្ដូរ និងកែលម្អ
- ពិនិត្យឡើងវិញអំពីការគ្រប់គ្រង ថែទាំ ការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិរដ្ឋដែលមានឱ្យបានត្រឹមត្រូវ

- វាយតម្លៃលើភាពសន្សំសំចៃ និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងកំណត់ការកែលម្អលើការអនុវត្តប្រតិបត្តិការ និងអនុសាសន៍
- ពិនិត្យឡើងវិញលើប្រតិបត្តិការកម្មវិធី និងគម្រោងចំណាយមូលធនលើលទ្ធផលការងារវិជ្ជមាន ឬអវិជ្ជមាន តាមគោលបំណង គោលដៅដែលបានដាក់ចេញ និងតាមផែនការដែលបានកំណត់
- ចូលរួមបង្កើតផែនការ ការអភិវឌ្ឍ ការអនុវត្ត និងប្រតិបត្តិការ លើប្រព័ន្ធកុំព្យូទ័រសំខាន់ៗដើម្បីធានាឲ្យ ៖
    - តម្រូវការរបស់អ្នកប្រើប្រាស់ត្រូវបានកំណត់ច្បាស់លាស់
    - ការត្រួតពិនិត្យផ្ទៃក្នុងសមស្របត្រូវបានបញ្ចូលទៅក្នុងកុំព្យូទ័រ
    - ការសាកល្បងនៃប្រព័ន្ធកុំព្យូទ័រត្រូវបានប្រព្រឹត្តទៅក្នុងជំហានសមស្រប
    - ការកត់ត្រាពីប្រព័ន្ធកុំព្យូទ័រត្រូវបានធ្វើពេញលេញ និងមានភាពត្រឹមត្រូវ
- ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធ ដំណើរការទិន្នន័យសំខាន់ៗក្រោយពេលដំឡើងរួច ដើម្បីកំណត់ប្រព័ន្ធទាំងនេះឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក ហើយទទួលលទ្ធផលមានសុវត្ថិភាព និងប្រសិទ្ធភាពការងារខ្ពស់
- ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្ត ដើម្បីធានាថាវិធានការបានដាក់ចេញក្នុងគោលបំណងការពារចំពោះការកេងបន្លំ។ ប្រសិនបើមានការកេងបន្លំកើតឡើង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកឃើញបានទាន់ពេលវេលា
- ពិនិត្យឡើងវិញលើការអនុវត្តតាមគោលការណ៍ណែនាំ និងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលស្តីពីឥរិយាបថ និងក្រមសីលធម៌របស់មន្ត្រីរាជការ
- វាយតម្លៃផែនការ ឬ សកម្មភាពកែលម្អ លើចំណុចរកឃើញរបស់សវនករផ្ទៃក្នុង។ ប្រសិនបើសកម្មភាពកែលម្អនេះមិនមានលក្ខណៈសមស្របទេនោះ ត្រូវលើកយកមកពិភាក្សាបន្តដើម្បីឱ្យសម្រេចតាមសំណូមពរដែលអាចទទួលយកបាន
- តាមដានសកម្មភាពកែលម្អលើអនុសាសន៍
- ធ្វើរបាយការណ៍ និងសន្និដ្ឋាននៃសវនកម្មផ្ញើជូនដល់ផ្នែកនីមួយៗ ដែលទទួលបន្ទុកកែលម្អតាមអនុសាសន៍ និងបញ្ជូនរាល់របាយការណ៍ និងសន្និដ្ឋានទៅជូនថ្នាក់ដឹកនាំក្រសួង និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ
- រក្សាទុកដាក់របាយការណ៍សវនកម្ម និងឯកសារគាំទ្រពាក់ព័ន្ធនានាឲ្យបានត្រឹមត្រូវ មានសុវត្ថិភាព និងរៀបរយតាមឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ ១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១២ .-**

ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគន៍ អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគ្គាធិការដ្ឋាន វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន គ្រប់នាយកដ្ឋាន គ្រប់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ និងអង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ប្រាក់ សុខុន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត

 « ដើម្បីជូនជ្រាប »
- ដូចប្រការ ១២

 « ដើម្បីអនុវត្ត »
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

LUAr133

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ បទ.ប្រក ចុះថ្ងៃទី ខែ ឆ្នាំ២០១៤

**អង្គការលេខនាយកដ្ឋានសវនកម្មផ្ទៃក្នុង**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ០០៤២ [illegible]

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-យោងលិខិតលេខ ៧៩៥/១៤ គ.វ.ក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្វ្លាយវើក (ខេមបូឌា) ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វ្លាយវើក (ខេមបូឌា) (FLYWORKS (CAMBODIA) Co., Ltd.) តំណាងដោយ លោកស្រី RIDING L RAINY សញ្ជាតិអាមេរិក អាយុ៦២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 443528204 ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ 690 North 100 East Logan, UT 84321. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្ភារៈសន្ទូចត្រី | ៣២៣០ |

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រផលិតសម្ភារៈសន្ទូចគ្រប់ប្រភេទ ហ្វាយវើក (ខេមបូឌា)"*
**ទីតាំងរោងចក្រ៖** *"ផ្ទះលេខ១៦៨បេ ផ្លូវ១០១៣ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញ បច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។ ៗកៗ

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹង ត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់ កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។/៣

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ០០៤៤ ឧស្ស.ក.ប្រក

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ៩៣២/១៤ គ.រ.ក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ណាម ក្វាង (ខេមបូឌា) ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ណាប ក្វាង (ខេមបូឌា) (NAM KWANG (CAMBODIA) CO., LTD.) តំណាងដោយ លោក LEE JONGWON សញ្ជាតិកូរ៉េ អាយុ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខNW1444017 ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ មានអាសយដ្ឋានបច្ចុប្បន្ន៖ Sanggye-dong, Chungsong bldg B02, 1619, Dongil-ro, Nowon-gu, Seoul, Korea ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| អំបោះ | ១៣១១ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រខាត់អំបោះ ណាម ក្វាង (ខេមបូឌា) "*
**ទីតាំងរោងចក្រ៖** *"ភូមិប្រទះឡាង សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។៚

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -សាលារាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ